ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ៖ ០៣០/២៤ ក.ប/ស.ជ.ណ.ខ.ល

## សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យដំណើរការនូវប្រអប់បណ្តឹងអនាមិក

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីធានានូវគណនេយ្យភាព តម្លាភាព និងសុចរិតភាពនៃការផ្តល់សេវាសាធារណៈរបស់ក្រសួង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ឱ្យដំណើរការប្រអប់បណ្តឹងអនាមិកដែលសាធារណជនអាចដាក់ពាក្យបណ្តឹងអនាមិក តាមរយៈគេហទំព័រ https://feedback.mlvt.gov.kh ឬអាចភ្ជាប់តាមរយៈការស្កេន QR Code ខាងក្រោម។

ក្នុងន័យនេះ ដើម្បីបង្ការការឆបោក ឬការមិនទទួលខុសត្រូវរបស់បុគ្គលណាមួយ ជាថ្មីម្តងទៀត ក្រសួង សូមជូនដំណឹង និងលើកទឹកចិត្តដល់សាធារណជន កម្មករនិយោជិត និងនិយោជក សូមប្រើប្រាស់នូវប្រអប់បណ្តឹងអនាមិកនេះ ដើម្បីទទួលបានការឆ្លើយតបពីក្រសួងនូវរាល់មតិ ឬសំណើនានា ព្រមទាំងឆ្លើយតបទៅនឹងចម្ងល់ ឬភាពមិនពេញចិត្ត ឬភាពមន្ទិលសង្ស័យ ឬចង់ប្តឹងបុគ្គលណាមួយ ដោយពុំមានតម្រូវឱ្យបង្ហាញអត្តសញ្ញាណរបស់ម្ចាស់បណ្តឹងនោះឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

ប្រអប់បណ្តឹងអនាមិក